**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៣១៩ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# រូបសញ្ញានិងត្រារបស់ក្រសួងអធិការកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៩ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអធិការកិច្ច

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតរូបសញ្ញានិងត្រារបស់ក្រសួងអធិការកិច្ច សម្រាប់ប្រើជាផ្លូវការក្នុងដំណើរការការងាររបស់ខ្លួន។

**មាត្រា២ .-**

រូបសញ្ញារបស់ក្រសួងអធិការកិច្ច មានទម្រង់និងអត្ថន័យដូចខាងក្រោម៖

**១-ទម្រង់**

- រូបភាពទូទៅនៃរូបសញ្ញាមានរាងជាទ្រវែងស្រួចលើ ព័ទ្ធដោយក្បូរស្រូវរាងស្នែងក្របី រូបរាងខាងក្នុងមានជើងពានទ្រូរដ្ឋធម្មនុញ្ញនិងទ្រព្រះខ័នបញ្ឈរបញ្ចេញចព្វណ្ណរង្សី ផ្នែកខាងក្រោមមានបូរំលេចឈ្មោះក្រសួងអធិការកិច្ច

- ទទឹងប្រវែង ៣ ភាគ ៤ នៃបណ្តោយ
- រូបសញ្ញាទាំងមូលរំលេចដោយពណ៌មាស ពណ៌ខៀវ ពណ៌ក្រហម និងពណ៌ស។

**២-អត្ថន័យ**

- ជើងពានទ្រវដ្តធម្មនុញ្ញ តំណាងឱ្យច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់អប់រំ ផ្សព្វផ្សាយ ណែនាំ ឱ្យមានការគោរពនិងអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ដែលជានាដល់ការលើកកម្ពស់អភិបាលកិច្ចនៃគ្រប់ស្ថាប័ន គ្រប់ថ្នាក់ ការពង្រឹងយុត្តិធម៌ និងសមធម៌សង្គម
- ព្រះខ័នបញ្ឈរលើជើងពានបញ្ចេញធព្វណ្ណរង្សីជះចេញ តំណាងឱ្យអំណាចដែលរាជរដ្ឋាភិបាលប្រគល់ជូនតាមច្បាប់សម្រាប់អនុវត្តតួនាទី ភារកិច្ច ប្រកបដោយការទទួលខុសត្រូវ ភាពម៉ឺងម៉ាត់ យុត្តិធម៌ និងមានគំនិត ប្រាជ្ញា ស្មារតីមោះមុត និងត្រចះត្រចង់
- កួរស្រូវទាំងសងខាង បង្ហាញពីភាពត្រជាក់ត្រជុំ សេចក្តីសុខក្សេមក្សាន្ត សុភមង្គល និងតំណាងឱ្យរាជធានី និងខេត្ត ទូទាំងព្រះរាជាណាចក្រកម្ពុជា
- ក្បាច់ផ្កាចន្ទន៍ និងភ្ញីទេស តំណាងឱ្យអរិយធម៌ វប្បធម៌ ភាពថ្កុំថ្កើងរុងរឿង
- បូមានពណ៌ខៀវនិងមានពណ៌ក្រហមរំលេចឈ្មោះក្រសួងអធិការកិច្ចពណ៌សចំកណ្តាល តំណាងឱ្យទង់ជាតិរបស់ព្រះរាជាណាចក្រកម្ពុជា។

រូបសញ្ញារបស់ក្រសួងអធិការកិច្ចដែលមានទម្រង់និងអត្ថន័យដូចបានចែងខាងលើ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**មាត្រា៣ .-**

រូបសញ្ញារបស់ក្រសួងអធិការកិច្ច ត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការរបស់ក្រសួងអធិការកិច្ច
- ដាក់លើក្បាលលិខិត ឯកសារ និងស្រោមសំបុត្រផ្លូវការរបស់ក្រសួងអធិការកិច្ច
- បំពាក់លើឯកសណ្ឋានមន្ត្រីរាជការក្របខ័ណ្ឌរបស់ក្រសួងអធិការកិច្ច
- ធ្វើត្រា
- ធ្វើប្រទីប
- ធ្វើកន្លាស់ពាក់ខ្នាស់នៅលើឯកសណ្ឋាន
- ធ្វើជាវត្ថុអនុស្សាវរីយ៍ជូនភ្ញៀវកិត្តិយសរបស់ក្រសួងអធិការកិច្ច
- ប្រើប្រាស់ជាផ្លូវការសម្រាប់ក្រសួងអធិការកិច្ច ក្នុងករណីផ្សេងទៀត។

**មាត្រា៤ .-**

ក្រសួងអធិការកិច្ចមានត្រាមួយប្រើសម្រាប់ប្រតិបត្តិការការងារ។

ត្រាមូលរបស់ក្រសួងអធិការកិច្ចមានវ័ណ្ឌពីរជាន់ រំលេចដោយកួរស្រូវរាងស្វែងក្របី ព័ទ្ធជើងពានទ្រវដ្តធម្មនុញ្ញ និងទ្រព្រះខ័នបញ្ឈរបញ្ចេញធព្វណ្ណរង្សី ខាងក្រោមមានបូរំលេចឈ្មោះក្រសួងអធិការកិច្ច។ ផ្នែកខាងលើមានឆ្លាក់អក្សរ **ព្រះរាជាណាចក្រកម្ពុជា** ស្របតាមវ័ណ្ឌ ផ្នែកខាងក្រោមមានឆ្លាក់អក្សរ **ក្រសួងអធិការកិច្ច** ស្របតាមវ័ណ្ឌ និងនៅចន្លោះពាក្យទាំងពីរ មានរូបផ្កាចន្ទន៍អមសងខាង។

ត្រារបស់ក្រសួងអធិការកិច្ចដែលមានទម្រង់ដូចបានចែងខាងលើ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអធិការកិច្ច រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងអធិការកិច្ច**

**ហួត ហាក់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ៣១១អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣

រូបសញ្ញារបស់ក្រសួងអធិការកិច្ច

ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ៣១៧អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣

ត្រារបស់ក្រសួងអធិការកិច្ច